# មេរៀនទី ៤៥៖ បងៗរបស់យ៉ូសែបលក់គាត់ឱ្យធ្វើជាទាសករ

## លោកុប្បត្តិ ៣៧៖១២-៣៦

**មេរៀន** ( *យូធូបលីង* )៖ https://youtu.be/B0T0BJ-UE8c

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/VKIlf0JKoCc

**គោលបំណង៖ ចង់ឱ្យយើងចេះស្រឡាញ់គ្នាទៅវិញទៅមក។**

**ខគម្ពីរចងចាំ៖ យ៉ូហាន១៣៖៣៤** *“ខ្ញុំឲ្យសេចក្ដីបញ្ញត្ត១ថ្មីដល់អ្នករាល់គ្នា គឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ”* ។

**ចំរៀង** ( *យូធូបលីង* )៖

១. ខ្ញុំឱ្យបញ្ញត្តិមួយថ្មី https://youtu.be/lio2oGzBFz8

២. ព្រះយេស៊ូវស្រលាញ់កុមារណាស់ https://youtu.be/8iUI62Zo_Co

៣. ក្តីស្រលាញ់នៃផ្អែមហើយអស្ចារ្យ https://youtu.be/W7hfRd0undE

## ១. អធិស្ឋាន

អរគុណព្រះអង្គសំរាប់ថ្ងៃថ្មី ជីវិតថ្មី នាំឱ្យយើងមកជុំគ្នានៅទីនេះ សូមដឹកនាំកូនឱ្យយល់ពីមេរៀន នៅថ្ងៃនេះ នៅក្នុងព្រះនាមព្រះអម្ចាស់ព្រះយេស៊ូវ! អាម៉ែន

## ២. ចំរៀង

*សូមច្រៀងចម្រៀងដែលមានលីង នៅក្នុងយូធូបលីងខាងលើ*

## ៣. ល្បែងកំសាន្ត “ ល្បែងផ្ទុយគ្នា ”




១. វាមានសារៈសំខាន់ណាស់សំរាប់យើងដែលត្រូវធ្វើអ្វីតាមពាក្យដែលយើងនិយាយ បើសិនជាយើងនិយាយថាយើងនឹងមានសន្តានចិត្តល្អ ដូច្នេះហើយយើងត្រូវតែចិត្តល្អ។

២. ឥឡូវនេះយើងនឹងលេងហ្គេមមួយគឺសិស្សនឹងធ្វើអ្វីដែលផ្ទុយនឹងសំដីរបស់គ្រូនិយាយ។

- ក្រោកឈរឡើង!( សិស្សនឹងអង្គុយ )
- អង្គុយចុះ!( សិស្សនឹងក្រោកឈរ )
- ដាក់ដៃចុះប្អូនៗ( សិស្សលើកដៃឡើង )

- នៅឱ្យស្ងៀម( សិស្សងាកចុះងាកឡើង )
- ងាកទៅឆ្វេង( សិស្សងាកទៅស្តាំ )
- កុំរាំ( សិស្សរាំ )។

៣. តើប្អូនពិបាកទេនៅពេលដែលធ្វើអ្វីផ្ទុយពីពាក្យដែលខ្ញុំនិយាយ? ព្រះចង់ឱ្យយើងធ្វើតាមទ្រង់ ព្រះអង្គមិនចង់ឲ្យយើងធ្វើខុសពីអ្វីដែលទ្រង់ប្រាប់យើងនោះទេ!

## ៤. ការណែនាំពីមេរៀន

ក្នុងសាច់រឿងកាលពីសប្តាហ៍មុន យើងបានរៀនពីក្រុមគ្រួសាររបស់យ៉ាកុប។ ក្នុងចំណោមកូនទាំង១២របស់គាត់ យ៉ូសែបជាកូនសំណព្វរបស់របស់យ៉ាកុប។ យ៉ូសែបបានប្រាប់ឪពុកពីរឿង មិនល្អរបស់បងគាត់ ហើយបន្ទាប់មកយ៉ូសែបបកស្រាយពីសុបិន្តដែលបង្ហាញថាក្រុមគ្រួសារគាត់នឹង ឱនគោរពគាត់។ នៅសប្តាហ៍នេះយើងនឹងរៀនពីអ្វី ដែលបានកើតឡើងនៅក្នុងគ្រួសាររបស់យ៉ាកុប ដែលគេមិនបានស្រលាញ់គ្នាទៅវិញទៅមកដូចដែលព្រះបានស្រលាញ់ពួកគេ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃមួយយ៉ាកុបបានប្រាប់យ៉ូសែបឱ្យទៅរកបងៗទាំង ១០ របស់គាត់។ ពួកគេបាននាំចៀមទៅយ៉ាងឆ្ងាយដើម្បីរកចំណី។ យ៉ូសែបកំពុងតែដើររកបងៗរបស់គាត់ ក៏បានលឺសំលេងចៀមយំពីចំងាយ ហើយយ៉ូសែបក៏ដើរសំដៅទៅកន្លែងនោះ។ បងៗរបស់គាត់បានឃើញគាត់កំពុងដើរមក ហើយដោយមានចិត្តខឹងនិងច្រណែននឹងយ៉ូសែបផងនោះ ពួកគេក៏ចាប់ផ្តើមរៀបគម្រោងធ្វើមិនល្អដាក់យ៉ូសែប។ ខ្លះនិយាយថា ពួកគេចង់ធ្វើបាបយ៉ូសែប ហើយខ្លះទៀតនិយាយថា ចង់កំចាត់យ៉ូសែបចោល។

នៅពេលដែលយ៉ូសែបដើរទៅកៀកនឹងបងៗ ពួកបងក៏បានចាប់យ៉ូសែបទំលាក់ចូលអណ្តូងយ៉ាងជ្រៅដែល យ៉ូសែបមិនអាចឡើងមកវិញបាន។ រូបេនបងប្រុសច្បងមានគំរោងត្រឡប់ទៅកន្លែងអណ្តូងវិញដើម្បីជួយសង្គ្រោះយ៉ូសែប តែយូដាជាអ្នកដែលមិនចង់ឱ្យយ៉ូសែបស្លាប់នៅក្នុងអណ្តូង ក៏ឱ្យយោបល់ថាលក់យ៉ូសែប ឱ្យធ្វើជាទាសកររគេទៅ។ បន្ទាប់មកពួកបងៗបានលក់យ៉ូសែបធ្វើជាទាសករឱ្យអ្នក ជំនួញមួយចំនួនដែលកំពុងធ្វើដំណើរទៅអេហ្ស៊ីប។

ពេលដែលបងៗរបស់យ៉ូសែបត្រឡប់ទៅផ្ទះវិញ ពួកគេប្រាប់ឪពុកថាយ៉ូសែបស្លាប់ហើយ។ ឪពុករបស់យ៉ូសែបគិតថា សត្វសាហាវបានសំលាប់យ៉ូសែបហើយ យ៉ាកុបកើតទុក្ខជាខ្លាំង។ បងៗរបស់យ៉ូសែបត្រូវរស់នៅជាមួយនឹងការកុហកនេះ។ យ៉ូសែបបានក្លាយជាទាសករនៅអេហ្ស៊ីប។

## ៦. សំនួរពិភាក្សា

១. តើបងៗរបស់យ៉ូសែបបានបង្ហាញក្តីស្រលាញ់ចំពោះប្អូនពួកគេដែលឬទេ? *( អត់ទេ )*

២. តើសកម្មភាពអ្វីខ្លះដែលបងៗរបស់យ៉ូសែបបានធ្វើដាក់គាត់? *(បងៗចាប់ប្អូនទំលាក់ទៅក្នុងអណ្តូង និងលក់គាត់ឱ្យទៅធ្វើជាទាសករ)*

៣. តើប្អូននឹងធ្វើបែបណានៅពេលដែលប្អូនខឹងនឹងបងប្អូនបង្កើតរបស់ប្អូន? *(ព្យាយាមនិយាយរកពួកគេ ហើយអត់ ទោសឱ្យពួកគេ សូមចិត្តទូលាយជាមួយពួកគេព្រោះព្រះមានព្រះទ័យល្អជាមួយយើងដែរ)*

## ៧. ល្បែងកំសាន្ត " ខ្លែងឆាបកូនមាន់ "



១. បែងចែកកុមារជា ២ក្រុម ឬច្រើនជាងនេះ

២. ក្នុងក្រុមនីមួយៗកុមារត្រូវតោងចង្កេះគ្នា។ អ្នកដែលនៅឈរមុខគេគឺត្រូវតាមចាប់យកអ្នកក្រោយគេនៃក្រុមផ្សេងទៀត ហើយក៏ត្រូវព្យាយាមការពារកូនក្រុមខ្លួនឯងផងដែរ (កន្ទុយក្រោយគេ)

៣. គោលបំណងនៃហ្គេមនេះគឺបង្ហាញពីការព្យាយាមការពារគ្នាទៅវិញទៅមក។ ក្រុមដែលតោងគ្នាមិនជាប់ (នឹងចាញ់ហ្គេមនេះដោយស្វ័យប្រវត្តិ) ហើយក្រុមដែលមានសមាជិករបស់ខ្លួនត្រូវគេចាប់បានក៏ចាញ់ហ្គេមនេះដែរ។

## ៩. ខគម្ពីរចងចាំ

**យ៉ូហាន១៣:៣៤** *"ខ្ញុំឲ្យសេចក្តីបញ្ញត្ត១ថ្មីដល់អ្នករាល់គ្នា គឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅ មក ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ"* ។

**កាយវិការចងចាំខគម្ពីរ**

- លើកដៃទាំងពីរទៅលើរួចប្រើចង្អុលដៃទាំងសងខាងចង្អុលទៅលើនិយាយថា (ខ្ញុំឱ្យ)
- ទម្លាក់ដៃទាំងពីរទៅខាងមុខ លាបាតដៃ (សេចក្តីបញ្ញត្តិ)
- លើកដៃម្ខាងធ្វើជាសញ្ញាលេខ 1 អាចប្រើចង្អុលដៃ (១ ថ្មី)
- ដាក់ដៃទាំង ២ ទៅខាងមុខ យកបាតដៃខ្ទេងគ្នា (ដល់អ្នករាល់គ្នា គឺឱ្យអ្នករាល់គ្នា)
- យកដៃទាំង២ ធ្វើរូបបេះដូង (ស្រឡាញ់គ្នា)
- លាបាតដៃទាំងពីរទៅមុខ (ទៅវិញ)
- ទាញដៃទាំងពីរត្រលប់មករកខ្លួនយើងវិញ (ទៅមក)
- យកដៃទាំង២ ធ្វើរូបបេះដូង(ត្រូវឱ្យស្រឡាញ់គ្នាដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ)។

## ១០. ហត្ថកម្ម "ខ្ញុំស្រលាញ់អ្នក " ដៃ




១. បត់ក្រដាសពាក់កណ្តាលហើយដាក ដៃ អ្នកដានលើ ក្រដាសនោះ



២. បត់ក្រដាសតាមដានដៃរបស់អ្នក ប៉ុន្តែកុំកាត់ផ្តាច់គែមនៃមេដៃ និងម្រាមដៃចង្អុល



៣. សូមលាដៃទាំងសងខាងហើយសរសេរថា” ខ្ញុំស្រលាញ់អ្នក” ហើយយកក្រដាសជូនដល់ឪពុកម្តាយប្អូន(ឬបងប្អូនស្រីប្រុសរបស់ប្អូន)

**១១. ចំរៀង**

*សូមជ្រើសរើសចម្រៀងមួយបទខាងលើហើយច្រៀងជាមួយសិស្ស*

**១២. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូះ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ក្នុងនាមយើងជាគ្រីស្ទបរិស័ទចាស់ទុំម្នាក់ យើងប្រឈមមុខនឹងបញ្ហារាល់ថ្ងៃក្នុងការធ្វើល្អ។ សូមអានសាច់រឿងម្តងទៀតពីរ៉ូបេន និងយូដា ហើយពិចារណាមើលពីស្ថានភាពពិបាកនៅក្នុង សាច់រឿង។ តើអ្នកធ្លាប់ប្រឆាំងតវ៉ាដើម្បីធ្វើអ្វី ដែលត្រឹមត្រូវទេក្នុងពេលដែលអ្នកផ្សេងរើសផ្លូវ ធ្វើរឿងមិនត្រឹមត្រូវយ៉ាងងាយសរសេររឿងរ៉ាវរបស់អ្នកអាទិត្យនេះ ហើយចែកចាយវាជាមួយ កុមារនៅក្នុងក្រុមជំនុំរបស់អ្នក។ សាច់រឿងរបស់អ្នកអាចនឹងលើកទឹកចិត្តនរណាម្នាក់ផ្សេងទៀតដើម្បីឲ្យគេធ្វើការល្អ។